00402537

D164/4/12

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 11 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២៤)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 17 / 11 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៩

---

សាធារណៈ:

## សេចក្តីសម្រេចលើសំណើសុំឲ្យមានការបំភ្លឺអំពីសេចក្តីអះអាងរបស់អង្គបុរេជំនុំជម្រះ

---

**សហព្រះរាជអាជ្ញា**

ជា លាង

William SMITH

**ជនត្រូវចោទ**

ខៀវ សំផន

អៀង ធីរិទ្ធ

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន — Silke STUDZINSKY
Martine JACQUIN
ឡោ ជុនធី — Philippe CANONNE
នី ចាន់ឌី — Pierre Olivier SUR
គង់ ពិសី — Elizabeth RABESANDRATANA
Olivier BAHOUGNE
យុង ផានិត — David BLACKMAN
គីម ម៉េងឃី — Annie DELAHAIE
Fabienne TRUSSES-NAPROUS
ម៉ុច សុវណ្ណារី — Patrick BEAUDOIN
ស៊ិន សុវ៉ន — Marie GUIRAUD
LYMA NGUYEN

**សហមេធាវីការពារក្តី**

ស សុវាន

Jacques VERGÈS

ផាត់ ពៅសៀង

Diana ELLIS

សុន អរុណ

Victor KOPPE
Michiel PESTMAN

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "សំណើសុំឱ្យមានការបំភ្លឺអំពីសេចក្តីអះអាងរបស់អង្គបុរេជំនុំជម្រះ" ដែលដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទកាលពីថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ ("សំណើសុំ")[១]។

១. នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច ទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥" ("សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញ")[២]។

២. នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សំណើសុំ។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញ នៅក្នុងសំណើសុំ សហមេធាវីការពារក្តីបានលើកសេចក្តីសម្អាងនៅក្នុងសេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញ ដែលសេចក្តីសម្រេចនេះជាប់ពាក់ព័ន្ធទាំងសំណុំរឿងអ.ប.ជ ២៤ និង អ.ប.ជ ២៥, ដោយសារសហមេធាវីការពារក្តីបានដាក់ស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះថា "អង្គបុរេជំនុំជម្រះយល់ឃើញថា ភាគីមិនអាចបង្ខំឱ្យអង្គបុរេជំនុំជម្រះអនុវត្តនីតិវិធីទេ ហេតុដូច្នេះអង្គបុរេជំនុំជម្រះ មិនមានកាតព្វកិច្ចដោះស្រាយរាល់ទឡ្ហីករណ៍ដែលបានលើកឡើងនោះទេ"។ អង្គបុរេជំនុំជម្រះចាត់ទុកសំណើនេះត្រឹមកម្រិតសំណុំរឿងអ.ប.ជ ២៤ ដោយសារសំណើនេះដាក់នៅក្នុងក្របខណ្ឌសំណុំរឿងនេះប៉ុណ្ណោះ ហើយជនត្រូវចោទមិនមានសិទ្ធិជាភាគីនៅក្នុងសំណុំរឿង អ.ប.ជ ២៥ ឡើយ។

៤. សំណើសុំមានបំណងសុំការបំភ្លឺពីអង្គបុរេជំនុំជម្រះទាក់ទងនឹងសំអាងហេតុដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចពីមុន ដែលជនត្រូវចោទមិនយល់ស្របនឹងសេចក្តីសម្រេចនោះ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សេចក្តីសម្រេចរបស់អង្គតុលាការ គឺជាសេចក្តី

---

[១] មេធាវីការពារក្តី អៀង ធីរិទ្ធ "សំណើសុំឱ្យមានការបំភ្លឺអំពីសេចក្តីអះអាងរបស់អង្គបុរេជំនុំជម្រះ" ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩, D164/4/11 ("សំណើសុំ")។

[២] សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច ទាក់ទងនឹងសំណើសុំឱ្យមានសវនាការ ដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥, ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើសំណើសុំឱ្យពិនិត្យមើលឡើងវិញ"), D164/4/9។

សម្រេចស្ដាពរ រួមបញ្ចូលទាំងសំអាងហេតុរបស់សេចក្ដីសម្រេច ដូចនេះអង្គតុលាការមិនអាចធ្វើការបកស្រាយបន្ថែមនោះទេ។ សំណើសុំខ្វះខាតនូវមូលដ្ឋានផ្នែកច្បាប់ និងមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង។

៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អង្គបុរេជំនុំជម្រះបានផ្ដល់សេចក្ដីបំភ្លឺពីមុនរួចហើយដល់ជនត្រូវចោទ នៅពេលដាក់នូវសំណើសុំ[៣]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សេចក្ដីបំភ្លឺពីមុននេះបានរៀបរាប់អំពីដំណាក់កាលនីតិវិធី ដែលអង្គបុរេជំនុំជម្រះបានសម្រេច បន្ទាប់ពីមានការប្ដឹងទាក់ទងនឹងទង្វើមិនស្មើភាពគ្នា។ បញ្ហាចោទមានលក្ខណៈខុសគ្នាពីសំណើសុំបច្ចុប្បន្ន ដែលសំណើសុំបច្ចុប្បន្នស្នើសុំឲ្យបំភ្លឺលើសេចក្ដីសម្រេច។

៦. ដោយយោងទៅលើការពិចារណាដូចបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះសម្រេចបដិសេធសំណើសុំនេះ។

ភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩

ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន

[៣] សេចក្ដីបំភ្លឺអំពីទង្វើមិនស្មើភាពគ្នាដែលបានចោទប្រកាន់